**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៦៧៥ សហវ.ប្រក-ពណ៧

រាជធានីភ្នំពេញ ថ្ងៃទី០៧ ខែសីហា ឆ្នាំ ២០០៧

# ប្រកាសអន្តរក្រសួង
## ស្តីពី
## កម្រៃរដ្ឋបាលក្នុងការចុះបញ្ជីពាណិជ្ជកម្ម

**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**
**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី ១៥ ខែ កក្កដា ឆ្នាំ ២០០៤ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៦ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦៩៥/០៤ ចុះថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១៩៩/១២ ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ១៩៩៩ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីវិសោធនកម្មលើច្បាប់ស្តីពីវិធានពាណិជ្ជកម្ម និងបញ្ជីពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦០៥/០១៩ ចុះថ្ងៃទី ១៩ ខែ មិថុនា ឆ្នាំ ២០០៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហគ្រាសពាណិជ្ជកម្ម
- បានឃើញព្រះរាជក្រមលេខ ០១/នស/៩៣ ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តី

អំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុ សម្រាប់ការគ្រប់គ្រងឆ្នាំ ១៩៩៥ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ១០/នស/៩៤ ចុះថ្ងៃទី ៣១ ខែ ធ្នូ ឆ្នាំ ១៩៩៤ និងត្រូវបានកែប្រែដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០០ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២៩៩/១៥ ចុះថ្ងៃទី ២៥ ខែ ធ្នូ ឆ្នាំ ១៩៩៩ ត្រូវបានកែប្រែដោយច្បាប់វិសោធនកម្មមាត្រា ២៦ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសឱ្យប្រើដោយច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០០៧ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៦/០៣៥ ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ និង ប្រកាសលេខ ១៤០១ សហវ.ប្រក ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៦ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាទូទៅរបស់រដ្ឋ

- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ២២ ខែ កញ្ញា ឆ្នាំ ១៩៩៧ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងពាណិជ្ជកម្ម
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៧៨ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ វិច្ឆិកា ឆ្នាំ ២០០៤ ស្តីពីការបំពេញបន្ថែម និងកែសម្រួលនាយកដ្ឋានមួយចំនួន នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អនុវត្តតាមអនុក្រឹត្យលេខ ៨២ អនក្រ.បក ចុះថ្ងៃទី ១៦ ខែ វិច្ឆិកា ឆ្នាំ ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- អនុវត្តតាមបទបញ្ជារបស់រាជរដ្ឋាភិបាលកម្ពុជា លេខ ០៤ បប ចុះថ្ងៃទី ១៥ ខែ វិច្ឆិកា ឆ្នាំ ២០០៦ ស្តីពីការពង្រឹងការគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- អនុវត្តតាមប្រកាសលេខ ០០៤ សហវ.មប្រក ចុះថ្ងៃទី ១៥ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការអនុវត្តនីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- បានឃើញប្រកាសលេខ ៥១៤ សហវ.ថហ ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០០ ស្តីពីការកំណត់អាករលើបែបបទសុំចុះឈ្មោះ លុបឈ្មោះ ឬ ចេញវិញ្ញាបនបត្រផ្សេងៗ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- អនុវត្តតាមសារាចរណែនាំ លេខ ០០២ សហវ.ម ចុះថ្ងៃទី ១៦ ខែ កុម្ភៈ ឆ្នាំ ១៩៩៦ ស្តីពីរជ្ជទេយ្យចំណូល
- អនុវត្តតាមសារាចរណែនាំលេខ ០០១ សហវ ចុះថ្ងៃទី ១៣ ខែ មករា ឆ្នាំ ២០០៤ ស្តីពីការកែលំអនីតិវិធីអនុវត្តថវិកា
- យោងតាមការចាំបាច់ក្នុងទិសដៅកែទម្រង់ ការចុះបញ្ជីពាណិជ្ជកម្មរបស់ក្រសួងពាណិជ្ជកម្ម

## សម្រេច

**ប្រការ ១ :** អនុញ្ញាតឱ្យយកកម្រៃរដ្ឋបាល ក្នុងការចុះបញ្ជីពាណិជ្ជកម្ម ។

**ប្រការ ២** : កម្រៃរដ្ឋបាលក្នុងការចុះឈ្មោះក្រុមហ៊ុន លុបឈ្មោះក្រុមហ៊ុន និង ចេញវិញ្ញាបនបត្រផ្សេងៗ ក្នុងបញ្ជីពាណិជ្ជកម្ម ត្រូវបានកំណត់ដូចខាងក្រោម :

| បរិយាយ | កម្រៃសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម | កម្រៃសុំលុបឈ្មោះចេញពីបញ្ជីពាណិជ្ជកម្ម | កម្រៃសុំវិញ្ញាបនបត្រផ្សេងៗ |
|---|---|---|---|
| **១. ក្រុមហ៊ុនពាណិជ្ជកម្ម** | **៤២០.០០០ រៀល** | **២០០.០០០ រៀល** | **៦០.០០០ រៀល** |
| ក្នុងនោះ : | | | |
| - ការសុំចុះឈ្មោះ | ២៦០.០០០ រៀល | | |
| - ទម្រង់បែបបទសុំចុះបញ្ជីពាណិជ្ជកម្ម | ១២០.០០០ រៀល | | |
| - ឆែកឈ្មោះ | ២០.០០០ រៀល | | |
| - ផ្តល់អត្តលេខ | ២០.០០០ រៀល | | |
| **២. សហគ្រាសឯកបុគ្គល ឬ ពាណិជ្ជករ ដែលជាប់ពន្ធលើប្រាក់ចំណេញ** | **១២០.០០០ រៀល** | **៦០.០០០ រៀល** | **២០.០០០ រៀល** |

**ប្រការ ៣** : ការបង់ប្រាក់ និង ការទទួលប្រាក់ចំណូលពីកម្រៃរដ្ឋបាល ក្នុងការចុះបញ្ជីពាណិជ្ជកម្ម ត្រូវអនុវត្តតាមរយៈរជ្ជទេយ្យករចំណូលនៅក្រសួងពាណិជ្ជកម្ម ។

**ប្រការ ៤** : **ក**-ការគ្រប់គ្រងចំណូលពីកម្រៃរដ្ឋបាល ក្នុងការចុះបញ្ជីពាណិជ្ជកម្ម ត្រូវអនុវត្តតាមនីតិវិធីនៃកិច្ចប្រតិបត្តិការថវិកាទូទៅរបស់រដ្ឋ និងត្រូវបានកត់ត្រា ក្នុងជំពូក ៧៣ គណនី ៧៣២ អនុគណនី ៧៣២៣ ដោយត្រូវបង់ ១០០% ចូលថវិការដ្ឋ ។

**ខ**-ក្រសួងពាណិជ្ជកម្មត្រូវបូកសរុបធ្វើរបាយការណ៍ចំណូលប្រចាំខែ រួចផ្ញើមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (នាយកដ្ឋានចំណូលមិនមែនសារពើពន្ធ) ឱ្យបានទៀងទាត់ ។

**ប្រការ ៥** : ការផ្តល់ប្រាក់ឧបត្ថម្ភ ដល់ការគ្រប់គ្រងលើការប្រមូលចំណូលនេះ នឹងត្រូវរៀបចំប្រកាសអន្តរក្រសួងមួយដោយឡែក តាមគោលការណ៍សម្រេចរបស់រាជរដ្ឋាភិបាល ។

**ប្រការ ៦** : ប្រកាសលេខ ៥១៤ សហវ.ថហ ចុះថ្ងៃទី ១៧ ខែ កក្កដា ឆ្នាំ ២០០០ ស្តីពីការកំណត់អាករលើបែបបទសុំចុះឈ្មោះ លុបឈ្មោះ ឬ ចេញវិញ្ញាបនបត្រផ្សេងៗ របស់ក្រសួង

សេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងប្រកាសលេខ ១៦២ MOC/M 2004 ចុះថ្ងៃទី ២៣ ខែ សីហា ឆ្នាំ ២០០៤ ស្តីពីការកំណត់សោហ៊ុយចំណាយលើបែបបទសុំចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ត្រូវចាត់ទុកជានិរាករណ៍ ។

**ប្រការ ៧ :** គ្រប់អង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និង ក្រសួងពាណិជ្ជកម្ម ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ។

**ប្រការ ៨ :** ប្រកាសនេះមានអនុភាពគតិយុត្តិ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ ។

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ

គាត ឈន់

ទេសរដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម

ចម - ប្រសិទ្ធ

<u>ចម្លងជូន :</u>

- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ទីស្តីការគណៈរដ្ឋមន្ត្រី
- អាជ្ញាធរសេវនកម្មជាតិ
- គ្រប់ក្រសួង-ស្ថាប័នពាក់ព័ន្ធ
- គ្រប់ខេត្ត-ក្រុង
- ដូចប្រការ ៧ ដើម្បីអនុវត្ត
- ឯកសារ-កាលប្បវត្តិ